**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..២៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ

## ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

មាត្រា ១.-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ :

-ទីតាំងស្ថិតក្រោមការកាន់កាប់របស់ក្រសួងសាធារណការ និងដឹកជញ្ជូនចំនួន០២កន្លែង រួមមានៈ

.ទីតាំងមួយផ្នែកនៃនាយកដ្ឋានសម្ភារៈ ទំហំដី ៨.៣៧៤ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវលេខ ១៣៨ និង

ផ្លូវលេខ ១៩៦ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

.ទីតាំងសាខានាយកដ្ឋានសម្ភារៈក្រុងព្រះសីហនុទំហំដី១៤.៧០៥ ម៉ែត្រក្រឡា ស្ថិតនៅបណ្ដោយផ្លូវជាតិលេខ៤ មណ្ឌល១ សង្កាត់លេខ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ។

-ទីតាំងស្ថិតក្រោមការកាន់កាប់ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ចំនួន ០៥ កន្លែង រួមមានៈ

.អគ្គនាយកដ្ឋានសុរិយោដី ទំហំដី១.១០៦ម៉ែត្រក្រឡា នៅផ្លូវលេខ១៦៣ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

.នាយកដ្ឋានភូមិសាស្ត្រ ទំហំដី៧៦៨ ម៉ែត្រក្រឡា នៅផ្លូវលេខ៦៥ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

.សហគ្រាសសំណង់ភ្នំពេញ ទំហំដី១៤៤.៥០ ម៉ែត្រក្រឡា នៅផ្លូវលេខ ២៩៩ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

.សហគ្រាសសិក្សាស្រាវជ្រាវ និង គូរប្លង់ ទំហំដី ២២០ ម៉ែត្រក្រឡា នៅផ្លូវប៉ាស្ទ័រ សង្កាត់ផ្សារថ្មី ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

.មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានីភ្នំពេញ ទំហំដី ១.៣០០ ម៉ែត្រក្រឡា នៅផ្លូវលេខ ៣២៨ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-ទីតាំងដីបំរុងសំរាប់ចំណតរឺម៉ក និង ម៉ូតូ ខេត្តកំពត ទំហំ៣.២៤៨ម៉ែត្រក្រឡា ស្ថិតក្រោមការកាន់កាប់ របស់សាលាខេត្តកំពត។

-ទីតាំងសាលាឃុំស្វាយប៉ោ ស្រុកបាត់ដំបង មានទំហំដី ១៦០ ម៉ែត្រក្រឡា ដែលស្ថិតក្រោមការកាន់កាប់ របស់សាលាខេត្តបាត់ដំបង។

-ទីតាំងអាគារ២ល្វែង ដីទំហំ១៦២ម៉ែត្រក្រឡា ក្រោមការកាន់កាប់របស់សាលាខេត្តបាត់ដំបង។

### មាត្រា ២.-

ការកត់ត្រាទ្រព្យសម្បត្តិថ្មីដែលទទួលបានពីការដោះដូរ ចូលក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រសួងសាធារណការ និង ដឹកជញ្ជូន ក្រសួងអប់រំ យុវជន និង កីឡា សាលាខេត្តបាត់ដំបង សាលាខេត្តកំពត និង មន្ទីរជំនាញពាក់ព័ន្ធ ស្របគោលការណ៍របស់រាជរដ្ឋាភិបាល ស្ដីពីការធ្វើឯកជនភាវូបនីយកម្ម។

### មាត្រា ៣.-

ការបំពេញបែបបទធ្វើកម្មសិទ្ធិរបស់ភាគីឯកជនលើទីតាំងរបស់រដ្ឋ ត្រូវប្រព្រឹត្តទៅតាមច្បាប់ និង គោលការណ៍កំណត់ជាធរមាន។

### មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អភិបាលខេត្តបាត់ដំបង អភិបាលខេត្តកំពត និង ប្រធានមន្ទីរជំនាញពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋាន រដ្ឋសភា
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការ រាជរដ្ឋាភិបាល
-ដូចមាត្រា ៥
-ឯកសារ-កាលប្បវត្តិ